# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

## ព្រឹត្តិបត្រព័ត៌មាន

ប.ស.ស

ឆ្នាំទី០៨

លេខ២១

ឆ្នាំ២០១៨









- ធានាសន្តិសុខប្រាក់ចំណូល
- រួមចំណែកកាត់បន្ថយភាពក្រីក្រ
- លើកកម្ពស់ស្ថិរភាពសង្គម

លេខទំនាក់ទំនងបន្ទាន់

២៤ម៉ោង/៧ថ្ងៃ





# លិខិតជូនពរ

## សូមជូនពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរចំពោះ

## សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក

## លោកស្រី អ្នកនាង កញ្ញា

## ក្នុងឱកាស ចូលឆ្នាំថ្មី ឆ្នាំសកល ២០១៨

**សូមទទួលបាននូវសុខភាពល្អ កម្លាំងមាំមួន អាយុយឺនយូរ**
**ប្រាជ្ញាឈ្លាសវៃ ជួបតែសុភមង្គល វិបុលសុខគ្រប់ប្រការ**
**ព្រមទាំងជោគជ័យគ្រប់ភារកិច្ច ប្រកបដោយពុទ្ធពរទាំងបួនប្រការ**
**គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

**សូមគោរពជូនពរពី**

ខ្ញុំបាទ **អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
នាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ព្រមទាំងមន្ត្រីរាជការ និងបុគ្គលិកក្រោមឱវាទទាំងអស់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
មន្ទីរព័ត៌មានរាជធានីភ្នំពេញ
លេខ..៣.៣.៤./ល.អពមរ
/១៧

ភ្នំពេញ,ថ្ងៃទី..០៤..ខែ..ធ្នូ.......ឆ្នាំ២០១៧

# លិខិតអនុញ្ញាត

## ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ

យោង: -ប្រកាសលេខ១០៨៣.ម.ប្រ.ក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៨ របស់ក្រសួងព័ត៌មាន។

-លិខិតអនុញ្ញាតលេខ០០៨/១៧ល.អ.ព.ម.រ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

-ពាក្យស្នើសុំអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ របស់លោក **ជាវ ប៊ុនរិទ្ធ** ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម**។

តាមសេចក្ដីយោងខាងលើនេះ មន្ទីរព័ត៌មានរាជធានីភ្នំពេញ សូមជម្រាបជូនមកលោក **ជាវ ប៊ុនរិទ្ធ** ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ជ្រាបថា មន្ទីរព័ត៌មានរាជធានីភ្នំពេញ អនុញ្ញាតឲ្យលោកចាងហ្វាងបន្តដំណើរការបោះពុម្ពផ្សាយចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ដែលមានទីស្នាក់ការនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតអនុញ្ញាតលេខ០០៨/១៧ ល.អ.ព.ម.រ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

ក្នុងដំណើរការបោះពុម្ពផ្សាយ លោកចាងហ្វាងត្រូវគោរពអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសរបស់ក្រសួងព័ត៌មាន ដូចយោងខាងលើ។

ករណីប្រព្រឹត្តល្មើស នឹងប្រកាសអនុញ្ញាតរបស់ក្រសួងព័ត៌មាន សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១ (មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានមន្ទីរ**

**យុត_សំខាន់**

***កន្លែងទទួល***
-ក្រសួងព័ត៌មាន
-អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
-សាលារាជធានីភ្នំពេញ
(ដើម្បីជ្រាបជាព័ត៌មាន)
-កងរាជអាវុធហត្ថរាជធានីភ្នំពេញ
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-ឯកសារ-កាលប្បវត្តិ

# មាតិកា




| | | |
|---|---|---|
| ០១. | ព្រះមហាក្សត្រ យាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បើកសម័យប្រជុំពេញអង្គលើកទី២៩ របស់ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម............ | ០១ |
| ០២. | កម្មករ កម្មការិនី វាយនភ័ណ្ឌ សាទរនឹងគោលនយោបាយសម្ដេចតេជោ ហ៊ុន សែន............ | ០២ |
| ០៣. | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ផ្ដល់យុទ្ធសាស្ត្រដើម្បីទប់ស្កាត់ និងកាត់បន្ថយបញ្ហាដួលសន្លប់............ | ០៤ |
| ០៤. | ប.ស.ស បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយធនាគារឯកទេសរីងស្ដីពីការប្រើប្រាស់សេវាកម្ម... | ០៦ |
| ០៥. | ប.ស.ស បើកកិច្ចប្រជុំស្ដីពីការធ្វើយុទ្ធនាការបង្កើនការផ្សព្វផ្សាយគោលនយោបាយរបស់ ប.ស.ស ជាមួយក្រុមហ៊ុន ១៧ Triggers............ | ០៨ |
| ០៦. | ក្រុមការងារ ក.ស.ថ.ម ប្រជុំពិនិត្យសម្រេចផ្ដល់អត្ថប្រយោជន៍ដល់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន | ០៩ |
| ០៧. | បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល............ | ១០ |
| ០៨. | ប.ស.ស បើកកិច្ចប្រជុំស្ដីពីគោលនយោបាយរបស់ ប.ស.ស ជាមួយសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា......... | ១១ |
| ០៩. | បណ្ណមូលនិធិសមធម៌សុខាភិបាលត្រូវបានផ្ដល់ជូនប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ នៅទូទាំងរាជធានីភ្នំពេញ............ | ១២ |
| ១០. | គោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមត្រូវបានយកទៅផ្សព្វផ្សាយដល់និយោជក............ | ១៤ |
| ១១. | កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ដល់និយោជក ............ | ១៦ |
| ១២. | ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ណែនាំឱ្យកម្មករចេះថែរក្សាសុខភាពសុវត្ថិភាព............ | ១៨ |
| ១៣. | អង្គការក្រៅរដ្ឋាភិបាលសប្បាយរីករាយចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល............ | ១៩ |
| ១៤. | បណ្ណមូលនិធិសមធម៌សុខាភិបាល ត្រូវបានផ្ដល់ជូនរដ្ឋបាលស្រុកចំនួន ០៣ក្នុងខេត្តត្បូងឃ្មុំ............ | ២០ |
| ១៥. | ទស្សនៈកិច្ចសិក្សាស្វែងយល់ពីប្រព័ន្ធព័ត៌មានវិទ្យា និងការគាំពារសង្គម នៅប្រទេសនេប៉ាល់............ | ២២ |
| ១៦. | កិច្ចប្រជុំពិភាក្សារបាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០១៧............ | ២៣ |
| ១៧. | ករណីដួលសន្លប់កម្មករ កម្មការិនីខេត្តពីរផ្សេងគ្នា ១៤៦នាក់ ទទួលបានការធានារ៉ាប់រង............ | ២៤ |
| ១៨. | កត្តាគីមីសាស្ត្រនៅតែជាបញ្ហាចម្បងដែលបណ្ដាលឱ្យមានការដួលសន្លប់របស់កម្មករ............ | ២៦ |
| ១៩. | កម្មករមកពីរោងចក្រ ០៦ផ្សេងគ្នាជួបគ្រោះថ្នាក់ចរាចរណ៍ បានទទួលការព្យាបាលដោយឥតគិតថ្លៃ............ | ២៧ |
| ២០. | ប.ស.ស បានចុះប្រគល់សម្ភារៈស្ថានីតិសម្បទាជូនជនរងគ្រោះ............ | ២៨ |
| ២១. | ការផ្ដល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋជូនដល់បុគ្គលិកនិង អ្នកជំនាញដោះមីន នៃប្រតិបត្តិករបោសសម្អាតមីន.......... | ៣០ |
| ២២. | ការផ្ដល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋជូនអ្នកធាក់ស៊ីក្លូ.. | ៣២ |
| ២៣. | ជំងឺលើសសម្ពាធឈាម និងទឹកនោមផ្អែមខ្លាចបន្លែ ៣មុខនេះ............ | ៣៤ |
| ២៤. | វិធីងាយៗកំចាត់មុន និងធ្វើឱ្យមុខស្រស់ថ្លា............ | ៣៤ |
| ២៥. | បណ្ដាំក្រមង៉ុយ............ | ៣៥ |
| ២៦. | កូនមាសពន្លក............ | ៣៦ |
| ២៧. | ទស្សនវិទូចិនលោក ខុងជឺ............ | ៣៧ |



**រចនាសម្ព័ន្ធព្រឹត្តិបត្រ**

**ឯកឧត្តម អ៊ុក សមវិទ្យា**

**នាយក ប.ស.ស**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តម **ជាវ ម៉ុនរិទ្ធ** |
| **និពន្ធនាយក** | លោក **ហែម សុគន្ធារិន** |
| **និពន្ធនាយករង** | លោក **នៅ សុមនា** |
| **លេខានិពន្ធ** | លោក **នាង ជូ** |
| | លោក **យន គន្ធា** |
| | លោក **លីម គក់** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **ពៅ សុវណ្ណារ៉ា** |
| | លោក **យង់ សុខន** |
| | លោក **ម៉ុត ស៊ីម** |


**អ្នកមានជួយអ្នកក្រ អ្នកសុខភាពល្អជួយអ្នកឈឺ**

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាបច្ចេកទេស
របបសន្តិសុខសង្គម (ក.ប.ស.ស.)

ក្រុមប្រឹក្សាភិបាល
នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

**នាយក**

**នាយករង**

ក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំ
ដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ
និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និង
បង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក)

ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាសម្រាប់
កំណត់គោលដៅអត្តសញ្ញាណជូនកម្មករនិយោជិត

ក្រុមការងារបច្ចេកទេសអន្តរក្រសួង
សម្រាប់ការងារចុះបញ្ជិកាមន្ត្រីសាធារណៈមកក្នុង ប.ស.ស

គណៈកម្មការវេជ្ជសាស្ត្រ
នៃ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង
នៃ ប.ស.ស

គណៈកម្មការវិនិយោគរបបសន្តិសុខសង្គម
នៃ ប.ស.ស

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក
សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក)
នៃ ប.ស.ស

- ការិយាល័យ សម្របសម្រួល និងទំនាក់ទំនងសាធារណៈ
- ការិយាល័យ ស្តារនីតិសម្បទា
- ការិយាល័យ សោធន
- ការិយាល័យ ព័ត៌មានវិទ្យា
- ការិយាល័យ ហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ
- ការិយាល័យ រដ្ឋបាល
- ការិយាល័យ អធិការកិច្ច និងកិច្ចការនីតិកម្ម
- ការិយាល័យ បញ្ជិកា និងភាគទាន
- ការិយាល័យ តាវកាលិក
- ការិយាល័យ គោលនយោបាយ
- ការិយាល័យ ធានារ៉ាប់រងសុខភាព
- ការិយាល័យ សវនកម្មផ្ទៃក្នុង

សាខា ប.ស.ស ខេត្ត-ខណ្ឌ

# ព្រះមហាក្សត្រខ្មែរ យាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ បើកសម័យប្រជុំពេញអង្គ លើកទី ២៩ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅក្នុងព្រះបរមរាជវាំង

ភ្នំពេញ៖ នៅព្រឹកថ្ងៃចន្ទ៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសម័យប្រជុំពេញអង្គលើកទី២៩ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅក្នុងព្រះបរមរាជវាំង ។



**កិច្ចប្រជុំនេះ រៀបចំឡើងដើម្បីពិនិត្យ សម្រេចនិងពិគ្រោះយោបល់លើរបៀបវារៈ ចំនួន ១១ រួមមាន៖**

**របៀបវារៈទី១** របាយការណ៍ស្តីពី សកម្មភាពការងាររបស់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចន្លោះសម័យប្រជុំលើកទី២៨ និងលើកទី២៩។

**របៀបវារៈទី២** ពិនិត្យ និងសម្រេចលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅ-ក្រម ទាក់ទងករណីចៅក្រមចំនួន១២រូប និងករណីព្រះអាជ្ញាចំនួន០៥រូប។

**របៀបវារៈទី៣** ពិនិត្យ និងសម្រេចលើសំណើសុំតែងតាំង ផ្ទេរភារកិច្ចប្រធាន អនុប្រធាន និង ចៅក្រមរាជ-ធានី/ខេត្ត មួយចំនួន។

**របៀបវារៈទី៤** ពិគ្រោះយោបល់លើសំណើសុំ តែងតាំងផ្លាស់ប្តូរ និងផ្ទេរភារកិច្ច ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងមួយ ចំនួនតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**របៀបវារៈទី៥** ពិគ្រោះយោបល់ លើសំណើសុំផ្តាច់ពីមុខងាររបស់ព្រះរាជអាជ្ញា ០១រូប នៃក្រសួងយុត្តិធម៌ទៅបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

**របៀបវារៈទី៦** ពិនិត្យ និង សម្រេចអំពីសំណើផ្ទេរក្របខណ្ឌចៅក្រម ០១ រូប នៃសាលាដំបូងខេត្តព្រៃវែង ឱ្យស្ថិតក្នុងក្របខណ្ឌព្រះរាជអាជ្ញានៃក្រសួងយុត្តិធម៌។

**របៀបវារៈទី៧** ពិនិត្យ និងសម្រេច លើសំណើសុំចូលនិវត្តន៍ពីក្របខណ្ឌចៅក្រមរបស់ **លោកជំទាវ ចែម វេយ្យរិទ្ធ**។

**របៀបវារៈទី៨** ពិនិត្យ និង សម្រេចពីការបន្តការងាររបស់ចៅក្រម ០១រូប នៃតុលាការកំពូល និងព្រះរាជអាជ្ញា ០១រូប នៃមហាអយ្យការអមតុលាការកំពូល ដែលមានអាយុ ៦៥ឆ្នាំ។

**របៀបវារៈទី៩** ពិនិត្យ និងសម្រេចលើសំណើសុំចូលបម្រើការងារវិញរបស់ចៅក្រម ០១រូប នៃសាលាឧទ្ធរណ៍ និងសុំអនុញ្ញាតច្បាប់ទៅបន្តការសិក្សារយៈពេល ០២ឆ្នាំ របស់ចៅក្រម ០១រូប នៃសាលាដំបូងខេត្តកណ្តាល។

**របៀបវារៈទី១០** ពិនិត្យ និង សម្រេចអំពីការដាក់ឱ្យបំពេញការងារនៅសាលាជម្រះក្តីវិញចំពោះចៅក្រម០១រូប។

**របៀបវារៈទី១១** បញ្ហាផ្សេងៗ ៕




# កម្មករ កម្មការិនី ទាយនភ័ណ្ឌ សាទរនឹង សម្ដេចតេជោ ហ៊ុន សែន ក្នុងពិធីជួបសំណេះសំណាល នៅតំបន់ផ្សារសំហាន់ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ភ្នំពេញ៖ ថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹង ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយបងប្អូនកម្មករ កម្មការិនីចំនួន ១៣ ៥៤៦នាក់ មកពីរោងចក្រចំនួន១៣ នៅក្នុងតំបន់ផ្សារសំហាន់ ស្ថិតនៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។



ក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនកម្មករកម្មការិនី **សម្ដេចតេជោ ហ៊ុន សែន** បានលើកឡើងពីការរីកចម្រើននៃទីក្រុងភ្នំពេញ ដែលមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ខុសប្លែកពីអតីតកាល ដែលក្រុងភ្នំពេញពីមុនគឺមិនមានអគារខ្ពស់ៗ និងអគ្គិសនី ប្រើប្រាស់គ្រប់គ្រាន់នោះទេ នៅតាមផ្ទះនីមួយៗភាគច្រើនគេប្រើតែចង្កៀងប្រេងកាតប៉ុណ្ណោះ។ ផ្ដើមចេញពីនេះ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានអបអរសាទរចំពោះកម្មករកម្មការិនី ដែលទទួលបានការតម្លើងប្រាក់ខែពី ១៥៣ ដុល្លារ ទៅ ១៧០ដុល្លារអាមេរិក ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរបស់បងប្អូនកម្មករ កម្មការិនីឱ្យកាន់តែប្រសើរ **សម្ដេចតេជោ** បានដាក់ចេញនូវសារសំខាន់ៗ ចំនួន០៨ចំណុច ដល់ក្រសួងពាក់ព័ន្ធដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងនោះរួមមាន៖

១. អនុវត្តន៍ប្រាក់ខែអប្បបរមា ១៧០ដុល្លារ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ។

២. ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាលត្រូវអនុវត្តការចុះពិនិត្យ ការព្យាបាលជំងឺដោយមិនបង់ប្រាក់នៅតាមមន្ទីរពេទ្យរដ្ឋដល់ កម្មករ កម្មការិនីទាំងក្នុងនិងក្រៅប្រព័ន្ធតាមរយៈមូលនិធិសមធម៌សុខាភិបាល រួមទាំងកីឡាករ កីឡាការិនី ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និង ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវអនុវត្តឱ្យបានម៉ត់ចត់ ។

៣. អនុវត្តន៍ការផ្តល់ជូនកម្មការិនីសម្រាលកូន នឹងទទួលបានការឈប់សម្រាកពីការងារចំនួន ០៣ខែ ហើយទទួលបានប្រាក់ឈ្នួល ១២០% (៥០%ចេញដោយនិយោជក និង ៧០%ទៀតចេញដោយបេឡាជាតិរបបសន្តិសុខសង្គម) ក្រសួងពាក់ព័ន្ធ ត្រូវតាមដានការងារឱ្យបានដិតដល់ចំពោះការអនុវត្តសកម្មភាព នេះ។

៤. អនុវត្តន៍ការឧបត្ថម្ភកម្មការិនីសម្រាលកូនបាន ០១នាក់ ទទួលបាន ថវិកា ៤០០ ០០០រៀល សម្រាលបានកូនភ្លោះ ០២នាក់ ទទួលបានថវិកា ៨០០ ០០០រៀល សម្រាលបានកូនភ្លោះ ០៣នាក់ ទទួលបានថវិកា ១ ២០០ ០០០-រៀល រួមទាំងថវិកាឧបត្ថម្ភចំនួន ៥ ០០០ ០០០រៀល ពី **សម្តេចតេជោ និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងការពិនិត្យ ផ្ទៃពោះដោយឥតគិតថ្លៃផងដែរ បើទោះបីជាសម្រាលកូន មកស្លាប់ក៏ដោយក៏ទទួលបានដូចគ្នា។

៥. អនុវត្តន៍របបសន្តិសុខសង្គម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៨ កម្មករ កម្មការិនី មិនជាប់កាតព្វកិច្ចបង់ភាគទានទេ គឺនិយោជកជាអ្នកបង់ជំនួស ១០០%។

៦. អនុវត្តន៍ការតាមដានលើបញ្ហាទឹក អគ្គិសនី ហើយចំពោះកម្មករកម្មការិនីដែលមិនទាន់មានទឹក អគ្គិសនី ប្រើប្រាស់ ដែលនៅតំបន់ឆ្ងាយ ត្រូវរៀបចំតបណ្តាញទឹក អគ្គិសនី ឱ្យបានឆាប់រហ័ស រួមទាំងស្នើសុំកុំឱ្យតម្លៃផ្ទះជួលឡើងថ្លៃសម្រាប់ឆ្នាំ ២០១៨នេះ។



៧. អនុវត្តន៍ប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ២០១៩ ជូនដល់កម្មករ កម្មការិនី ដូច្នេះក្នុងរយៈពេលពេញ ០១ឆ្នាំ២០១៨ នេះត្រូវរៀបចំឱ្យរួចរាល់ដើម្បីដំណើរការឱ្យបានល្អនូវរបបសោធននិវត្តន៍នេះ។

៨. អនុវត្តន៍ការចូលរួមបន្តយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ចំពោះពលករនៅក្រៅប្រទេស និង ជួយសម្រួលបែបបទ លិខិតបទដ្ឋានផ្លូវច្បាប់នានា ដើម្បីឱ្យទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរឡើង៕



# រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់យុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់បញ្ហាដួលសន្លប់របស់កម្មករ (៩ចំណុច)

ភ្នំពេញ៖ ដើម្បីអនុវត្តទៅតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបង្កើនការយកចិត្តទុកដាក់លើបញ្ហាដួលសន្លប់របស់កម្មករនិយោជិត គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ ដើម្បីទប់ស្កាត់ករណីដួលសន្លប់ ដែលមាន **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រធានបានបើកកិច្ចប្រជុំជាលើកទី១ ដើម្បីរកឱ្យឃើញនូវករណីដួលសន្លប់ឈានទៅទប់ស្កាត់និងលុបបំបាត់ឱ្យបានទាំងស្រុង។ កិច្ចប្រជុំនេះ ធ្វើឡើងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨



កិច្ចប្រជុំដើម្បីរកគ្រប់វិធីសាស្ត្រទប់ស្កាត់នូវករណីដួលសន្លប់ របស់បងប្អូន កម្មករនិយោជិត នៅតាមរោងចក្រ សហគ្រាស

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមមាន៖ **ភាគីរាជរដ្ឋាភិបាល ភាគីនិយោជក ភាគីសហជីព** និង អង្គការជាដៃគូពាក់ព័ន្ធ ក្នុងនោះមាន**អង្គការសុខភាពពិភពលោក (WHO) អង្គការ ILO-BFC** សម្រាប់ផ្តល់នូវបច្ចេកទេសពាក់ព័ន្ធក្នុងការរកវិធីទប់ស្កាត់ករណីដួលសន្លប់របស់បងប្អូនកម្មករនិយោជិត នៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន ជាពិសេស គឺ រោងចក្រកាត់ដេរ និង ផលិតស្បែកជើង។



**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានមានប្រសាសន៍ថា៖ អង្គប្រជុំបានពិនិត្យមើលគ្រប់ករណីដួលសន្លប់កន្លងមក និងវិភាគពីផ្នែកបច្ចេកទេស ផ្នែកចិត្តសាស្ត្រសង្គម ផ្នែកវេជ្ជសាស្ត្រមួយចំនួនដើម្បីប្រមូលធាតុចូលផ្តើមនូវវិធានការ និងបានបង្កើតក្រុម ការងារបច្ចេកទេសមួយជាសេនាធិការដែលមានក្រសួងការងារ និង ប ណ្តុះប ណ្តាល វិជ្ជាជីវៈ និង ក្រសួង សុខាភិបាល ជាសហប្រធានសម្រាប់ផ្នែកបច្ចេកទេសផ្តល់យោបល់ធ្វើយ៉ាងណាដើម្បីទប់ស្កាត់ ហើយឈានទៅរកការលុបបំបាត់ករណីដួលសន្លប់នេះទាំងស្រុងតែម្តង។ ទី២ រៀបចំនូវប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាលកំណត់នូវបទប្បញ្ញត្តិមួយចំនួនដើម្បីយកទៅអនុវត្ត ទី៣ បង្កើននូវកិច្ចប្រជុំផ្សព្វផ្សាយដល់បងប្អូនកម្មករនិយោជិតឱ្យមានការប្រុងប្រយ័ត្ន និងទី៤ បង្កើននូវវិធានការអនុវត្តច្បាប់ អនុវត្តពាក្យស្លោកសុវត្ថិភាពជាចម្បងមុនពេលធ្វើការដើម្បីបង្កើនប្រសិទ្ធភាពដូចជាបង្កើននូវអធិការកិច្ចការងារធានានូវអនាម័យ និងសុវត្ថិភាពការងារនេះនៅកន្លែងធ្វើការ៕







# បេឡាជាតិរបបសន្តិសុខសង្គម បានចុះហត្ថលេខាលើអនុស្សារណៈ យោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្ម ជាមួយធនាគារឯកទេសវីង(ខេមបូឌា) លីមីតធីត

ភ្នំពេញ៖ **បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្មរវាង **បេឡាជាតិរបបសន្តិសុខសង្គម និងធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត** ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ កាំបូឌីយ៉ាណា។



ឯកឧត្តមប្រតិភូ ថ្លែងសុន្ទរកថា

ពិធីនេះ ធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និងលោក Ruan Swanepoel នាយកជាន់ខ្ពស់ ទទួលបន្ទុកពាណិជ្ជកម្ម នៅព្រឹកថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានមានប្រសាសន៍ក្នុងពិធីចុះហត្ថលេខានេះថា ពិធីនេះធ្វើឡើងក្នុងគោលបំណង ផ្តល់សេវាបង់ភាគទាន និងទូទាត់តាវកាលិកជូនកម្មករ និយោជិត ដែលទទួលរងហានិភ័យការងារ សេវាថែទាំសុខភាព ការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់ស្ត្រីនៅពេលសម្រាលកូនឱ្យបានទាន់ពេលវេលា និងឆាប់រហ័សជាងមុន។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបន្ត ថា ប.ស.ស កំពុងពង្រីកវិសាលភាព ដោយអនុលោមតាមអនុ-សាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្ពោះទៅរកសេដ្ឋកិច្ចក្រៅប្រព័ន្ធបន្ថែម ដែលនេះជាឱកាស ប.ស.ស ត្រូវតែចាប់ដៃគូសហការក្នុងការផ្តល់សេវាជូនដល់កម្មករនិយោជិតឱ្យមានភាពល្អប្រសើរ និងមានភាពងាយស្រួលបន្ថែមទៀត។




បច្ចុប្បន្ន ប.ស.ស បានចុះបញ្ជិកាសរុបចំនួន ៩ ៣៦០សហគ្រាស មានកម្មករសរុបចំនួន ១ ១៧៩ ០៦០នាក់ ក្នុងនោះបានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញចំនួន ៨៤៨សហគ្រាសស្មើនឹងចំនួន ៩២៩ ៥០៦នាក់ និងបានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី/ខេត្ត បានចំនួន ១ ២៨៩មូលដ្ឋាន។ ជាមួយគ្នានេះ ប.ស.ស បានផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដល់កម្មករ កម្មការិនីចំនួន ៣៦០ ៤៣៩នាក់ ផងដែរ៕



កម្រងរូបភាពអនុស្សាវរីយ៍

# ប.ស.ស បើកកិច្ចប្រជុំស្តីពីការធ្វើយុទ្ធនាការបង្កើនការផ្សព្វផ្សាយគោលនយោបាយរបស់ ប.ស.ស ជាមួយក្រុមហ៊ុន ១៧ Triggers



ភ្នំពេញ៖ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៅថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ បានបើកកិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុន១៧ Triggers ស្តីពីយុទ្ធសាស្រ្តយុទ្ធនាការបង្កើនការផ្សព្វផ្សាយរបស់ ប.ស.សស្ថិតនៅសាលប្រជុំទីស្នាក់ការ កណ្តាល ប.ស.ស។



**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានមានប្រសាសន៍ថា កិច្ចប្រជុំពិភាក្សានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងឱ្យនិយោជក និងកម្មករនិយោជិត ទាំងអស់មានការយល់ដឹង អំពីអត្ថប្រយោជន៍របស់ ប.ស.ស ហើយត្រូវអនុវត្តតាមដំណាក់ៗកាល និងផ្តោតសំខាន់ទៅលើកញ្ចប់ព័ត៌មានយ៉ាងលម្អិតលើការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្សេងៗ មានដូចជា ហ្វេសប៊ុកផេច (Facebook page) ជាដើម ដើម្បីឱ្យនិយោជក កម្មករនិយោជិត រួមទាំងប្រជាពលរដ្ឋ ទាំងក្នុង និងក្រៅប្រទេសបានយល់ដឹងពី ប.ស.ស។



**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានមានប្រសាសន៍ បន្ថែមទៀតថា ត្រូវមានយុទ្ធនាការផ្សព្វផ្សាយអំពីមាតុភាព ការផ្តល់នូវការធានារ៉ាប់រងផ្សេងៗពេលមានជំងឺ និងការយកចិត្តទុកដាក់ផ្សព្វផ្សាយទៅលើបណ្តាញសង្គមផ្សេងៗ រួមមាន ហ្វេកប៊ុក (Facebook) យូធូប (YouTube) វេបសាយ (Website) អ៊ីម៉េល/សារ (Email/SMS) និងធាតុសំខាន់ផ្សេងៗ ទៀតរបស់ ប.ស.ស (NSSF Branches)។

ជាពិសេស **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានសង្កត់ធ្ងន់ទៅលើជំងឺដែលមានវត្តមានច្រើននៅប្រទេសកម្ពុជាហើយជម្រុញឱ្យមានការយកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យបានច្បាស់លាស់កុំឱ្យមានការយល់ច្រឡំពីសាធារណៈជនទូទៅ៕

# ក្រុមការងារ ក.ស.ថ.ម ប្រជុំពិនិត្យសម្រេចផ្តល់អត្ថប្រយោជន៍ ដល់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន



ភ្នំពេញ៖ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៅព្រឹកថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ បានរៀបចំកិច្ចប្រជុំពិភាក្សាការងារបច្ចេកទេសអន្តរក្រសួង ស្តីពីការរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែក ថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ (ក.ស.ថ.ម) លើកទី១៤ នៅអគារស្នាក់ការកណ្តាល នៃ ប.ស.ស ។





កិច្ចប្រជុំពិភាក្សានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីកែសម្រួលចុងក្រោយលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ផ្នែកហានិភ័យការងារ រួមមាន៖

- ការព្យាបាល និងថែទាំមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះបីសម្រាក ឬមិនសម្រាកនៅក្នុងមន្ទីរពេទ្យក្តី រហូតដល់ ជាសះស្បើយ។
- ការផ្តល់ឱសថសម្រាប់ការព្យាបាល និងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្តល់សេវាស្តារនីតិសម្បទា មានជាអាទិ៍ ការផ្តល់ ការថែទាំ ឬការជួសជុលឧបករណ៍អវយវៈ ឬសរីរាង្គសិប្បនិម្មិត ឬការកែទម្រង់រាងកាយដែលតម្រូវដោយគ្រូពេទ្យផ្លូវការ ការសម្របសម្រួលមុខងារ ឬការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈឡើងវិញ។
- ការផ្តល់សេវាដឹកសព ឬបញ្ជូនជនរងគ្រោះពេលសង្គ្រោះបន្ទាន់៕

# បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល ជូនសមាគមម៉ូតូកង់បី

ភ្នំពេញ៖ ដោយមានការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គមបានរៀបចំពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាលដល់សមាគមម៉ូតូកង់បីប្រមាណជា៤ ០០០បណ្ណ ស្ថិតនៅភោជនីយដ្ឋានរស្មីបឹងកក់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម។

ក្នុងពិធីនេះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានមានប្រសាសន៍ថាក្រោយពីទទួលបានទិន្នន័យពីការចុះបញ្ជិការបស់សមាគមម៉ូតូកង់បីកាលពីពេលថ្មីៗកន្លងទៅនេះ ប.ស.ស បានរៀបចំពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិ-បាលជូនបងប្អូនអ្នករត់ម៉ូតូកង់បីជាបន្តបន្ទាប់។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបន្ថែមថា នៅពេលបងប្អូនអ្នករត់ម៉ូតូកង់បីទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាលនេះបងប្អូនអាចទៅទទួលបានការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយឥតបង់ថ្លៃ។



ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម

ជាងនេះទៅទៀត **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបន្តទៀតថា នៅជំហានទី១ នេះ ប.ស.ស បានចុះបញ្ជីអ្នកបើកម៉ូតូកង់បីប្រមាណជាង ៤ ០០០នាក់ ហើយនឹងបន្តចុះបញ្ជីឱ្យអស់នៅទូទាំងប្រទេសនាពេលឆាប់ៗនេះ។

ពិសេសជាងនេះទៀត **សម្តេចតេជោ** បានផ្តល់គោលរបបឧបត្ថម្ភជាសាច់ប្រាក់សុទ្ធជូនដល់កម្មការិនីសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធដែលបានចុះបញ្ជីមកក្នុង ប.ស.ស។ ចាប់ពីម៉ោង ០០:០០នាទី ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ រហូតដល់ម៉ោង ៥:០០នាទី ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ប.ស.ស បានបើកផ្តល់ប្រាក់ឧបត្ថម្ភនេះដល់កម្មការិនី ទាំងក្នុង និងក្រៅប្រព័ន្ធដែលបានសម្រាលកូនបានចំនួន ២៨៨នាក់ និងបានបើកប្រាក់ឧបត្ថម្ភជាថវិកាសរុប ចំនួន ១១៥ ២០០ ០០០រៀល។ គោលរបបឧបត្ថម្ភជាសាច់ប្រាក់នេះ ទោះសម្រាលមកកូននោះស្លាប់ក៏ទទួលបានដែរ៕



ពិធីប្រគល់បណ្ណមូលនិធិសមធម៌ជូនដល់សមាគមម៉ូតូកង់បី

# ប.ស.ស បើកកិច្ចប្រជុំស្ដីពីគោលនយោបាយរបស់ ប.ស.ស ជាមួយសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា





ភ្នំពេញ៖ ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គមបានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និងមន្ត្រីពាក់ព័ន្ធ។

កិច្ចប្រជុំពិភាក្សានេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនជូនដល់សមាជិកសមាគម។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានរំលឹកអំពីបេឡាជាតិរបបសន្តិសុខសង្គម ដែលហៅកាត់ថា (ប.ស.ស) បានចាប់ផ្តើមអនុវត្តដំបូងលើការធានារ៉ាប់រង ផ្នែកហានិភ័យការងារ នៅឆ្នាំ២០០៨ បន្ទាប់មកនៅឆ្នាំ២០១៦ បានឱ្យអនុវត្តន៍លើផ្នែកថែទាំសុខភាពដែលមានសមាជិកសរុបចំនួន ១ ១៧០ ០០០ នាក់។

ម្យ៉ាងវិញទៀត ដោយយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីម៉ោង ០០:០០នាទី ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ ភាគីនិយោជក ត្រូវមានកាតព្វកិច្ចលើការបង់ភាគទានទាំងស្រុងលើផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ជំនួសឱ្យកម្មករនិយោជិតក្នុងប្រព័ន្ធវិញដោយអត្រាភាគទានត្រូវបង់សរុបគឺស្មើនឹង ៣,៤% (បីក្បៀសបួនភាគរយ) នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានហើយពិដាននៃប្រាក់ឈ្នួលខ្ពស់បំផុតគឺ មានចំនួន ១ ២០០ ០០០ រៀល។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានបន្តទៀតថា នៅពេលបច្ចុប្បន្ន នេះមានសាកលវិទ្យាល័យចំនួន៥៤ វិទ្យាល័យមានចំនួន៥៧ សាលាបឋមសិក្សា មានចំនួន២១៣ និងសាលាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈមានចំនួន១១៨សរុបទាំងអស់ស្មើនឹង ៤៤២គ្រឹះស្ថាន ហើយមានបុគ្គលិកទាំងអស់ ១៨ ៩៣៥នាក់ ដែលបានមកចុះបញ្ជីជាមួយ ប.ស.ស។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម ហេង វ៉ាន់ដា** ប្រធានក្រុមប្រឹក្សាភិបាល និងជាតំណាងសមាគម គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា បានមានចម្ងល់ និងសំណួរមួយចំនួនព្រមទាំងមានការសំណូមពរដល់ ប.ស.ស សុំឱ្យសមាគមបានចូលរួមផ្តល់មតិយោបល់មុននឹងសេចក្តីព្រាងប្រកាសនានាបានចេញជាផ្លូវការដើម្បីឱ្យសមាគមមានពេលវេលាត្រៀមខ្លួនជាមុន៕



# បណ្ណមូលនិធិសមធម៌សុខាភិបាល ត្រូវបានផ្តល់ជូនដល់ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ នៅទូទាំងរាជធានីភ្នំពេញ





ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាខណ្ឌដង្កោ

ភ្នំពេញ៖ **ឯកឧត្តម ប៉ែន នរៈឧុធ** នាយករង បេឡាជាតិរបបសន្តិសុខសង្គម បានចូលរួមជាអធិបតីភាពក្នុងពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាលនានា នៅក្នុងរាជធានីភ្នំពេញ ដើម្បីចែកជូនដល់ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ បានចំនួន ១០ខណ្ឌ សរុបទាំងអស់បានចំនួន ២ ០២៨បណ្ណ ដែលក្នុងនោះមានខណ្ឌដូនពេញបានចំនួន ៤១៣បណ្ណ ខណ្ឌដង្កោ ចំនួន ៣២៨បណ្ណ ខណ្ឌចំការមនចំនួន ២៧៤បណ្ណ ខណ្ឌ៧មករា ចំនួន ៩២បណ្ណ ខណ្ឌព្រែកព្នៅ ចំនួន ១៧៧បណ្ណ ខណ្ឌមានជ័យ ចំនួន ១៧៥បណ្ណ ខណ្ឌសែនសុខ បានចំនួន ១៦៩បណ្ណ ខណ្ឌច្បារអំពៅ ចំនួន ១៤៥បណ្ណ ខណ្ឌឫស្សីកែវ ចំនួន ៩០បណ្ណ និងខណ្ឌជ្រោយចង្វារ ចំនួន ៦៥បណ្ណ ដែលទិន្នន័យនេះ រាប់គិតត្រឹមថ្ងៃទី០១ ខែមករា មកដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ នេះ។



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាខណ្ឌច្បារអំពៅ



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាខណ្ឌជ្រោយចង្វារ

នៅឱកាសនោះផងដែរ **ឯកឧត្តម** បានជម្រាបជូនគ្រប់អង្គពិធីនានាថា៖ ដោយយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ មកចុះបញ្ជីចូលជាសមាជិក ប.ស.ស. ដើម្បីទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាល។ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ អាចទទួលបានការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយឥតគិតថ្លៃរួមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ នេះតទៅ៕



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល
នៅសាលាខណ្ឌមានជ័យ



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាឫស្សីកែវ



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាខណ្ឌសែនសុខ



ពិធីចែកបណ្ណមូលនិធិសមធម៌សុខាភិបាល នៅសាលាខណ្ឌ ៧មករា




កម្រងរូបភាពអនុស្សាវរីយ៍ នៅសាលាខណ្ឌមានជ័យ

# គោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ត្រូវបានយកទៅផ្សព្វផ្សាយ ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន នៅខេត្តកែប



កែបៈ ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ០៨:៣០នាទី បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយសាលាខេត្តកែប រៀបចំប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ក្រោមអធិបតីភាព **ឯកឧត្តម ម៉េង ហុង** នាយករង និងជាតំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកបេឡាជាតិរបបសន្តិសុខសង្គម និង **ឯក ឧត្តម សោម ពិសិដ្ឋ** អភិបាលស្តីទី និងជាតំណាងឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកែប លោកវេជ្ជបណ្ឌិត **ឡូន សេង** អនុប្រធានមន្ទីរសុខាភិបាលខេត្តកែប លោក **ស្រី សាម៉ន** អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប លោក **ស៊ីន កុសល** ប្រធាន ប.ស.ស សាខាខេត្តកែប លោកលោកស្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក លោកលោកស្រី ជាប្រធាន/អនុប្រធានមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងនិយោជក ម្ចាស់-សហគ្រាស គ្រឹះស្ថានឬតំណាងរួមទាំងជនរងគ្រោះដោយសារគ្រោះថ្នាក់ការងារទាំងអស់ដែលស្ថិតនៅក្នុងមន្ទីរពេទ្យខេត្តកែបដែលបាន ចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និងធនាគារអេស៊ីលីដានៅក្នុងខេត្តកែបផងដែរ។

**ឯកឧត្តមអភិបាល** ស្តីទី មានមោទកភាព និងសេចក្តីសោមនស្សរីករាយដែលបានចូល រួមក្នុងពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអនុវត្តរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។



**ឯកឧត្តម** បានមានប្រសាសន៍ថា ការធានារ៉ាប់រងលើសន្តិសុខសង្គម មានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងបរិបទដែលប្រទេសកម្ពុជា មានការរីកចម្រើនលើគ្រប់វិស័យដោយបានផ្តល់នូវការគាំពារសង្គម សម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ។ ម្យ៉ាងទៀតគោលនយោបាយសន្តិសុខសង្គមក៏រួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយកាត់បន្ថយភាព

ក្រីក្ររបស់រាជរដ្ឋាភិបាល តាមរយៈការបន្ថយនូវគម្លាតប្រាក់ចំណូលរវាងអ្នកមាន និងអ្នកក្រដើម្បីធានាឱ្យមានស្ថិរភាព និងភាពសុខដុមរម្យនាក្នុងសង្គម។



ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអភិបាល** ស្តីទី បានថ្លែងអំណរគុណដល់ បេឡាជាតិរបបសន្តិសុខសង្គម ក្នុងការផ្តល់នូវកិច្ចប្រជុំផ្សព្វផ្សាយនេះដល់តំណាងនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលជាក្បាលព្រួញសម្រាប់ផ្សព្វផ្សាយបន្តដល់កម្មករនិយោជិតឱ្យបានយល់ច្បាស់ពីសិទ្ធិក្នុងការទៅទទួលបានសេវានៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស មានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះធ្វើឡើងក្នុងគោលបំណងផ្សព្វ-ផ្សាយគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គមនិងវឌ្ឍនភាពរបស់ ប.ស.ស បញ្ហាប្រឈមជាពិសេសធ្វើការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករ-និយោជិត ការផ្តល់សេវារបស់មន្ត្រីសាខា ខេត្ត/ខណ្ឌ ការផ្តល់សេវារបស់មន្ទីរពេទ្យ និងធនាគារអេស៊ីលីដា ដែលបានចុះកិច្ចព្រមព្រៀង ។

**ឯកឧត្តម** ក៏បានបន្តថា បច្ចុប្បន្ន ប.ស.ស ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានសរុបចំនួន ៩ ៧២៩សហគ្រាស ស្មើនឹង ១ ១៨៦ ៤៥៣នាក់ និងមានមន្ទីរពេទ្យ មណ្ឌលសុខភាព ចុះកិច្ចព្រមព្រៀងផ្តល់សេវាដល់សមាជិក ប.ស.ស ចំនួន ១ ២៨៥ ផងដែរ ហើយកម្មករនិយោជិតបានទទួលនូវអត្ថប្រយោជន៍ពី ប.ស.ស រួមមាន៖ ការសង្គ្រោះបន្ទាន់ ការថែទាំ និងព្យាបាលសុខភាព ការទទួលបានប្រាក់បំណាច់ ប្រចាំថ្ងៃ ការទទួលបានធនលាភនិងផ្តល់ប្រាក់វិភាជន៍ សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី សេវាបុនទីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ៕



# កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន នៅសាលាខណ្ឌមានជ័យ




ភ្នំពេញ៖ នៅថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំកម្មវិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យការងារដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រោមអធិបតីភាព លោក **ពេជ្រ កែវមុនី** អភិបាល នៃគណៈអភិបាលខណ្ឌមានជ័យ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ប្រមាណជាង ១៥០នាក់ នៅសាលាខណ្ឌមានជ័យ ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ យល់ដឹងឱ្យកាន់តែច្បាស់ពីនីតិវិធីនៃការចុះបញ្ជីកម្មករនិយោជិត និងនីតិវិធីនៃការបង់ភាគទាន ដើម្បីទទួលបានសេវាពិនិត្យ និងព្យាបាលជម្ងឺដោយឥតគិតថ្លៃពី ប.ស.ស ។





**លោក ពេជ្រ កែវមុនី** បានមានប្រសាសន៍ថា ការធានារ៉ាប់រងមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជាហើយ នៅពេលបច្ចុប្បន្ននេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានផ្តល់ការគាំពារសង្គម ជូនបងប្អូនកម្មករ កម្មការិនីទាំងក្នុង និងក្រៅប្រព័ន្ធ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។

ទាំងនេះក៏ដោយសារមានការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានគិតគូពីសុខទុក្ខ និងសុខមាលភាពរបស់បងប្អូនកម្មករ កម្មការិនី និងប្រជាពលរដ្ឋទាំងអស់ ៕



# ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ណែនាំឱ្យកម្មករចេះថែរក្សា សុខភាពសុវត្ថិភាព និងយល់ដឹងពីអត្ថប្រយោជន៍ របបសន្តិសុខសង្គម



តាកែវ៖ **ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម** (**ក.ប.ស.ស.**) ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨ ដឹកនាំដោយ **ឯកឧត្តម ភាន់ ម៉ន** រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារបានចុះប្រជុំផ្សព្វផ្សាយអប់រំស្តីពីសុវត្ថិភាពការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដល់និយោជក កម្មករ កម្មការិនីនៅរោងចក្រចំនួន ០៣ រួមមាន រោងចក្រ **ហ្វាយស្តារ** រោងចក្រ **ហ៊ុខ ស៊ុន** និង រោងចក្រ **COPIOUS (CAMBODIA) INTERNATIONAL INC** ស្ថិតនៅស្រុកសំរោង ខេត្តតាកែវ។



ពិធីនេះមានការអញ្ជើញចូលរួមពី **ឯកឧត្តម អ៊ូច ភា** អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រីពាក់ព័ន្ធ និងកម្មករ កម្មការិនីប្រមាណជាង ២៥៩នាក់។

តំណាងរោងចក្រនីមួយៗ បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅ ព្រមទាំងរាយការណ៍ពីស្ថានភាពកម្មករ កម្មការិនីនៅក្នុងរោងចក្របានយ៉ាងក្បោះក្បាយ។ ក្នុងឱកាសនេះដែរតំណាងរោងចក្រទាំង ០៣ បានសម្តែងទឹកចិត្តសប្បាយចិត្តរីករាយយ៉ាងក្រៃលែងចំពោះបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលតែងតែយកចិត្តទុកដាក់ចំពោះបញ្ហាសុខុមាលភាពរបស់បងប្អូនកម្មករ កម្មការិនី នៅគ្រប់បណ្តារោងចក្រទូទាំងប្រទេសកម្ពុជា។

**ឯកឧត្តម** បានមានមតិសំណេះសំណាល និងសម្តែងនូវមោទកភាព ចំពោះ **ឯកឧត្តមប្រធាន** ក៏ដូចជាក្រុមការងារដែលបានមកប្រជុំផ្សព្វផ្សាយអប់រំសុវត្ថិភាពការងារ សុខភាព និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ជូនដល់បងប្អូនកម្មករ កម្មការិនី ដែលមានវត្តមាននៅក្នុងពិធីនេះ។ **ឯកឧត្តម** ក៏បានបន្តផ្តាំផ្ញើបន្ថែមដល់បងប្អូនកម្មករ កម្មការិនីទាំងអស់ ពីការខិតខំប្រឹងប្រែងរបស់ប្រមុខរាជរដ្ឋាភិបាលក្រោមការដឹកនាំដោយភាពប៉ិនប្រសព្វ និងឆ្លាតវៃរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខិតខំបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ដើម្បីជៀសឆ្ងាយពីល្បែងអបាយមុខនិងគ្រឿងញៀនដែលនាំឱ្យប៉ះពាល់ដល់សីលធម៌សង្គម។



ឆ្លៀតក្នុងឱកាសនេះដែរ **ឯកឧត្តមប្រធាន ក.ប.ស.ស.** បានមានប្រសាសន៍ថា កិច្ចប្រជុំផ្សព្វផ្សាយនេះធ្វើឡើងក្នុងគោលបំណងដើម្បីអប់រំសុខភាព សុវត្ថិភាពការងារ អនាម័យការងារ និងគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម និងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ហៅកាត់ថា (ក.ប.ស.ស.) ។ **ឯកឧត្តម** បានបន្តថា រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ចំពោះសុខទុក្ខបងប្អូន កម្មករ កម្មការិនីទូទាំងប្រទេស ដោយប្រកាសគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវខិតខំពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់ តែល្អប្រសើរបន្ថែមទៀត៕

# អង្គការក្រៅរដ្ឋាភិបាល សប្បាយរីករាយចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាលើប្រព័ន្ធគាំពារសង្គមរបស់ បេឡាជាតិរបបសន្តិសុខសង្គម

រាជធានីភ្នំពេញ៖ ថ្ងៃអង្គារ ០៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ។ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុញ្ញាតឱ្យគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជាហៅកាត់ថា គ.ស.ក ចូល ជួប ពិភាក្សា ដើម្បីស្នើសុំយោបល់ និងគោលនយោបាយស្តីពី ប.ស.ស ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ជាវ ម៉ុនរិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស។

**ឯកឧត្តម ជាវ ម៉ុនរិទ្ធ** បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះតំណាងគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាដែលបានអញ្ជើញចូលរួមកិច្ចប្រជុំនេះ និងបានលើកឡើងពីគោលការណ៍របស់បេឡាជាតិរបបសន្តិសុខសង្គម ។

**ឯកឧត្តម** បានបន្តទៀតថា ប.ស.ស មានបេសកកម្មចំនួន ០៣ធំៗ រួមមាន៖ **ផ្នែកហានិភ័យការងារ** ដែលដាក់ឱ្យអនុវត្តកាលពី**ឆ្នាំ២០០៨** **ផ្នែកថែទាំសុខភាព** បានដាក់ឱ្យដំណើរការ កាលពី**ឆ្នាំ២០១៦** កន្លងទៅ និង**ផ្នែកសោធន** ត្រៀមដាក់ឱ្យដំណើរការនៅ**ឆ្នាំ២០១៩** ខាងមុខនេះ ដោយយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្តម** ក៏បានពន្យល់បន្ថែម អំពីការពង្រីករបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព និងផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលជូនដល់ មន្ត្រីរាជការសាធារណៈ និងកម្មករ និយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ដើម្បីឱ្យពួកគាត់ទៅទទួលបានសេវាពីមូលដ្ឋានសុខាភិបាលសាធារណៈ ដោយឥតបង់ប្រាក់។

ប្រធានប្រតិបត្តិ គ.ស.ក លោក **ឃុន ម៉ុនថុង** បានរៀបរាប់ពីចំនួនអង្គការដែលបានចូលជាសមាជិករបស់ខ្លួនមានប្រមាណជាង ១៧០អង្គការដែលធ្វើការលើវិស័យផ្សេងៗគ្នា។ ក្នុងនោះដែរ លោក **ឃុន ម៉ុនថុង** បានជម្រាបជូនអង្គប្រជុំថា សមាជិក គ.ស.ក ទាំងអស់ពិតជាមានការសប្បាយរីករាយ ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្នែករបបសន្តិសុខសង្គមនេះណាស់។

ឆ្លៀតក្នុងឱកាសនោះផងដែរ លោកបានស្នើសុំឱ្យ ប.ស.ស ផ្តល់នូវវគ្គបណ្តុះបណ្តាលដល់អង្គការក្រៅរដ្ឋាភិបាលដើម្បីឱ្យសមាជិកទាំងអស់ បានយល់អំពីការទទួលបានអត្ថប្រយោជន៍ពី ប.ស.ស និងស្នើសុំកុំឱ្យដាក់ពិន័យ ចំពោះអង្គការក្រៅរដ្ឋាភិបាលណាដែលមិនទាន់បានអនុវត្តតាមសេចក្តីប្រកាសស្តីពីរបបសន្តិសុខសង្គម លើផ្នែកថែទាំសុខភាព៕



# បណ្ណមូលនិធិសមធម៌សុខាភិបាល
# ត្រូវបានផ្តល់ជូនរដ្ឋបាលស្រុកចំនួន០៣ ក្នុងខេត្តត្បូងឃ្មុំ

ត្បូងឃ្មុំ៖ ចាប់ពីថ្ងៃទី២៥ ខែមករា ដល់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ នេះ បេឡាជាតិរបបសន្តិសុខសង្គម ក្រោមអធិបតីភាព **ឯកឧត្តម ជាវ ម៉ុនរិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានចុះប្រគល់បណ្ណមូលនិធិសមធម៌សុខាភិបាលជូនដល់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ និងអតីតយុទ្ធជនស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ បានចំនួន ០៣ស្រុក សរុបទាំងអស់បានចំនួន ១ ៧២៥បណ្ណ រួមមាន៖

- ស្រុកត្បូងឃ្មុំ ចំនួន ៧២៣បណ្ណ
- ស្រុកពញាក្រែក ចំនួន ៧២៣បណ្ណ
- ស្រុកតំបែរ ចំនួន ២៧៩បណ្ណ

គោលបំណងនៃការចែកបណ្ណនេះគឺ ដើម្បីឱ្យទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទូទាំងប្រទេសដោយឥតគិតថ្លៃ និងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មការិនីសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធ។

**ឯកឧត្តម** មានប្រសាសន៍ រៀបរាប់អំពីវឌ្ឍនភាព របស់បេឡាជាតិរបបសន្តិសុខសង្គមដែលមានអត្ថន័យដូចតទៅ៖

១. អំពីសាវតា ប.ស.ស

២. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ការងារ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខៈ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២។

៣. បេឡាជាតិរបបសន្តិសុខសង្គមបង្កើតឡើងដោយអនុក្រឹត្យលេខ ១៦.អ.ន.ក្រ.បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

៤. បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាគ្រឹះស្ថានសាធារណរដ្ឋបាលដែលមានបេសកកម្មបម្រើសេវាសាធារណៈ



មានលក្ខណៈសង្គម ដែលមានជំហានអនុវត្តរួមមាន៖ ជំហានទី១ ផ្នែកហានិភ័យការងារ ជំហានទី២ ផ្នែកថែទាំសុខភាព ជំហានទី៣ និងផ្នែកប្រាក់សោធន។

៥. អនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។



៦. ព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

៧. អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់តាវ-កាលិក ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

៨. ប្រកាសអន្តរក្រសួងលេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្នុង និងក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។ ក្នុងនោះកម្មករនិយោជិតក្រៅប្រព័ន្ធ ត្រូវប្រើប្រាស់សេវាតាមប្រព័ន្ធផ្តល់សេវាថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់។ ករណីសង្គ្រោះបន្ទាន់ជនរងគ្រោះ ឬអ្នកមានជំងឺអាចទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត។ រីឯកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនបានមួយនាក់ទទួលបានថវិកា ៤០០ ០០០រៀល សម្រាលបានកូនភ្លោះពីរទទួលបានថវិកា ៨០០ ០០០រៀល និងសម្រាលបានកូនភ្លោះបីទទួលបានថវិកា ១ ២០០ ០០០រៀល ក្រោយពេលសម្រាល រួមទាំងថវិកាឧបត្ថម្ភបន្ថែមចំនួន ៥ ០០០ ០០០រៀល ពី **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បើទោះបីជាសម្រាលកូននោះមកស្លាប់ក៏ដោយក៏ទទួលត្រូវបានថវិកាឧបត្ថម្ភបន្ថែមដូចគ្នា។

គិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃ៣០ ខែមករា ឆ្នាំ២០១៨ នេះមានកម្មករនិយោជិតជាស្ត្រីទៅទទួលសេវាសម្រាលកូនមានចំនួន ៣ ៧៥៦នាក់ ដែលសម្រាលបានកូនសរុប ៣ ៧៨៨នាក់ (កម្មការិនីសម្រាលកូនភ្លោះពីរមាន ៣០ នាក់) ដែលទទួលបានថវិកាឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលតាមរយៈបេឡាជាតិរបបសន្តិសុខសង្គម។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តម** បានជម្រាបជូនអង្គប្រជុំថាដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន** គឺគ្រប់កម្មករនិយោជិត ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ រួមទាំងប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ទាំងអស់មានសិទ្ធិទទួលបានរបបគាំពារសង្គមពីរាជរដ្ឋាភិបាលតាមរយៈក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈដែលមាន ប.ស.ស ជាសេនាធិការបានរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្នុង និងក្រៅប្រព័ន្ធ និងការ ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រី នៅ ពេល សម្រាលកូនដែលបានចុះបញ្ជីជាសមាជិក ប.ស.ស។

ទន្ទឹមគ្នានោះ **សម្តេចតេជោ ហ៊ុន សែន** តម្រូវឱ្យប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ/សង្កាត់ មកចុះបញ្ជីចូលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមដើម្បីទទួលបានបណ្ណមូលនិធិសមធម៌សុខាភិបាលផងដែរ៕



# ទស្សនៈកិច្ចសិក្សាស្វែងយល់ពី ប្រព័ន្ធព័ត៌មានវិទ្យា និងការគាំពារសង្គម នៅប្រទេសនេប៉ាល់



ប្រទេសនេប៉ាល់៖ ដោយមានការសហការពីអង្គការ GIZ ប្រចាំប្រទេសកម្ពុជា និងអង្គការ GIZ ប្រចាំប្រទេសនេប៉ាល់ បានអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន០៤រូប ដឹកនាំដោយលោក **HUBERT ZANDER** អ្នកជំនាញការព័ត៌មានវិទ្យា(ប ស ស) ចូលរួមដំណើរការទស្សនៈកិច្ចស្តីពីការស្វែងយល់ការគាំពារសង្គម និងប្រព័ន្ធព័ត៌មានវិទ្យា រួមទាំងប្រព័ន្ធទិន្នន័យតាមរយៈទូរស័ព្ទ (Mobile Application)។



ដំណើរទស្សនៈកិច្ចនេះ ប្រព្រឹត្តិទៅចំនួន០៤ថ្ងៃ ចាប់ពីថ្ងៃចន្ទ ១០កើត ដល់ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុង **Kathmandu** ប្រទេសនេប៉ាល់។ គោលបំណងទស្សនៈកិច្ចសិក្សានេះធ្វើឡើងដើម្បីស្វែងយល់ពីប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងគម្រោងគាំពារសង្គម **(OpenIMIS operation in Nepal)** និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យតាមរយៈទូរស័ព្ទដៃ **(Mobile Application)** ដោយផ្តោតសំខាន់លើនីតិវិធីចុះបញ្ជិកា ការទូទាត់សំណង នីតិវិធីនៃការចូលរួមប្រើប្រាស់សេវា និងប្រព័ន្ធព័ត៌មាននៃការគ្រប់គ្រងគ្របដណ្តប់ ចំពោះកម្មករនិយោជិតវិស័យសេដ្ឋកិច្ចរៀបរយ និងមិនរៀបរយ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំអនុវត្តន៍នៅប្រទេសកម្ពុជាឱ្យបានល្អប្រសើរ និងជៀសវាងហានិភ័យកើតឡើងជាយថាហេតុ៕






# កិច្ចប្រជុំពិភាក្សារបាយការណ៍

## បូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក (ស.ផ.ក)



រាជធានីភ្នំពេញ៖ នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំកិច្ចប្រជុំពិភាក្សាលើរបាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម ក្រោមអធិបតីភាព **ឧត្តមសេនីយ៍ទោ លុយ ឈីន** អនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិក ព្រមទាំងមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាប្រមាណជា ១៥នាក់ ស្ថិតនៅក្នុងសាលប្រជុំ នៃស្នាក់ការកណ្តាល ប.ស.ស ។





កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងបង្ហាញពីសកម្មភាព និងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ របស់ក្រុមការងារដែលជាកិច្ចខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចរបស់ខ្លួនដើម្បីចូលរួមទប់ស្កាត់ និងកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍ និងលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោក របស់កម្មករនិយោជិតតាមរយៈការចុះប្រជុំអប់រំផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចណ៍ផ្លូវគោក ដល់កម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ការចុះបណ្តុះបណ្តាលប្រឡងបណ្ណបើកបរ និងផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត បណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជំនាញភ្នាក់ងារសង្គ្រោះបឋម ដល់រដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក សហជីពមូលដ្ឋាន គ្រូពេទ្យប្រចាំរោងចក្រ និងបំពាក់ប៉ាដាពាក្យស្លោក ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅតាមបណ្តារោងចក្រ ទូទាំងរាជធានី/ខេត្ត៕

# ករណីដួលសន្លប់កម្មករ កម្មការិនីខេត្តពីរផ្សេងគ្នា ១៤៦ នាក់ ទទួលបានការធានារ៉ាប់រងពី ប.ស.ស

កោះកុង៖ ករណីសន្លប់ នៅតែបន្តកើតឡើងចំពោះបងប្អូនកម្មករ កម្មការិនី និយោជិត ដែលជាក្តីកង្វល់របស់ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គម។



ជាការពិតនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨នេះ មានករណីសន្លប់មួយបានកើតឡើង ចំពោះកម្មករ កម្មការិនីដែលបម្រើការងារនៅក្រុមហ៊ុន **ខេខេអិន (KKN)** ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស ខេត្តកោះកុង។

ករណីសន្លប់ខាងលើ បណ្តាលឱ្យកម្មករ កម្មការិនីប្រមាណជាង ១៣០នាក់ បានសន្លប់តៗគ្នា (ជំងឺស្ទេហ៍ហ្វូង)។ មន្ត្រី ប.ស.ស សាខាខេត្តកោះកុង បានឱ្យដឹងថាមូលហេតុដែលបង្កឱ្យកើតមានការសន្លប់នោះ គឺមកពីមានការសាយភាយក្លិនប្រេងពីគ្រឿងចក្រ ដែលប្តូរនៅក្បែរនោះ។



ហេតុការណ៍ខាងលើនេះ ត្រូវបានមន្ត្រី និងក្រុមការងារ ប.ស.ស សាខាខេត្តកោះកុង បានចុះទៅជួយសម្របសម្រួលជាមួយរដ្ឋបាលក្រុមហ៊ុនបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង។

សូមបញ្ជាក់ថា រាល់ការចំណាយលើសេវាដឹកជញ្ជូនជនរងគ្រោះនិងថ្លៃសេវាព្យាបាលរហូតជាសះស្បើយ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងស្រុង៕





ព្រះសីហនុ៖ ដើម្បីបង្កើនការយកចិត្តទុកដាក់លើបងប្អូន កម្មករ កម្មការិនី គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារដើម្បី ទប់ស្កាត់បញ្ហាករណីដួលសន្លប់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកកិច្ចប្រជុំលើកទី១ ដើម្បីរកឱ្យឃើញនូវករណីដួល សន្លប់ ឈានទៅរកការទប់ស្កាត់ និងលុបបំបាត់ទាំងស្រុង។





នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨នេះ មានករណីសន្លប់មួយបានកើតឡើងចំពោះកម្មករ កម្មការិនី ដែលបម្រើការងារនៅរោងចក្រ CAMBODIAN STAYWILD SPORTS CO., LTD ក្នុងតំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅក្នុងភូមិពូធឿង ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ករណីសន្លប់ខាងលើនេះ បណ្តាលឱ្យកម្មករ កម្មការិនី ប្រមាណ១៦នាក់ដួលសន្លប់តៗគ្នា(ជំងឺស្នេហ៍ហ្វូង)។

មន្ត្រី ប.ស.ស សាខាខេត្តព្រះសីហនុ បានឱ្យដឹងថា មូលហេតុដែលបណ្តាលឱ្យ មានករណីសន្លប់ខាងលើនេះផ្តើមចេញពីកម្មការិនីម្នាក់មានអាការៈវិលមុខរួចគាត់សន្លប់ ហើយកម្មករ កម្មការិនី ផ្សេងទៀតឃើញហេតុការណ៍នេះទន់ដៃជើងសន្លប់តៗគ្នា។

ហេតុការណ៍ខាងលើនេះ ត្រូវបានមន្ត្រី និងក្រុមការងារ ប.ស.ស សាខាខេត្តព្រះសីហនុ បានចុះទៅជាមួយរដ្ឋបាលរោងចក្រដើម្បីជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅ **គ្លីនិក កែវ ចាន់តារា** ចំនួន១០នាក់ និង **គ្លីនិក សេតេ** ចំនួន០៦ នាក់។

សូមបញ្ជាក់ថា រាល់ការចំណាយលើសេវាដឹកជញ្ជូនជនរងគ្រោះនិងថ្លៃសេវាព្យាបាលរហូតជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងស្រុង៕






# កត្តាគីមីសាស្ត្រ នៅតែជាបញ្ហាចម្បង ដែលបណ្តាលឱ្យមានការដួលសន្លប់ របស់កម្មករ

តាកែវ៖ មានករណីដួលសន្លប់តៗគ្នារបស់កម្មករ កម្មការិនី នៅរោងចក្រ **សេឌូណា** ប្រមាណជា ៦៥ នាក់ កាលពីវេលាម៉ោង ៧:១៥នាទីព្រឹក ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ០២ ភូមិកណ្តឹងតូច ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ។





ក្រោយពេលទទួលបានដំណឹងមន្ត្រី **បេឡាជាតិរបបសន្តិសុខសង្គម** សាខាខេត្តតាកែវ បានសហការជាមួយរដ្ឋបាលរោងចក្រ **សេឌូណា** ធ្វើការសម្របសម្រួលរួចបញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់នៅ **គ្លីនិក សុខា បាទី** ដែលមានទីតាំងនៅក្បែរកន្លែងកើតហេតុនោះ។

មូលហេតុនៃការដួលសន្លប់របស់កម្មករ កម្មការិនីនេះ បណ្តាលមកពីមានការសាយភាយក្លិនថ្នាំបាញ់ស្រូវ ដែលប្រជាពលរដ្ឋបានបាញ់ស្រូវនៅស្រែជិតរោងចក្រ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨កន្លងទៅ។



សូមបញ្ជាក់ថា រាល់ការចំណាយលើសេវាដឹកជញ្ជូនជន រងគ្រោះនិងថ្លៃសេវាព្យាបាលរហូតជាសះស្បើយ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងស្រុង៕



# កម្មករមកពីរោងចក្រ ០៦ផ្សេងគ្នា ជួបគ្រោះថ្នាក់ចរាចរណ៍ និងទទួលបានការព្យាបាល ដោយឥតគិតថ្លៃ



ស្វាយរៀង៖ ជារៀងរាល់ថ្ងៃតែងតែមានគ្រោះថ្នាក់ជាហូរហែ ដែលបណ្តាលឱ្យមានអ្នកស្លាប់ របួសពិការ និងបានបន្សល់ទុកនូវសោកនាដកម្មគួរឱ្យរន្ធត់អាណោចអាធមជាទីបំផុត។ ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង៦:៤៨នាទីព្រឹក ស្ថិតនៅភូមិអង្គសាលា សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងនៅពេលដែលឡានកំពុងដឹកកម្មករ កម្មការិនីចេញពីផ្ទះឆ្ពោះទៅកន្លែងធ្វើការ ខណៈនោះស្រាប់តែមានម៉ូតូមួយគ្រឿងវ៉ាជែងរួចក៏ជ្រុលចង្កូតទៅប៉ះឡានដឹកកម្មករ កម្មការិនីចំនួន ១០៥នាក់ ។ ក្នុងនោះបានបណ្តាលឱ្យរងរបួសសរុបចំនួន ២២នាក់ (ស្រី ១៩នាក់) រងរបួសធ្ងន់ចំនួន ៣នាក់ ដែលពួកគាត់ធ្វើការក្នុងរោងចក្រចំនួន ៦ផ្សេងៗគ្នាដូចជា៖

| | |
|---|---|
| ១. ស៊ីកូ(ខេមបូឌា) ខូអិលធីឌី | ១២នាក់ |
| ២. ឡុងប្រាយ អេឡិកទ្រិក អេនធីប្រាយ | ០៣នាក់ |
| ៣. យីងម៉េកឃើ (ខេមបូឌា) ហ្វូតវែរ | ០១នាក់ |
| ៤. កៅវ៉េ ស្តុត | ០៤នាក់ |
| ៥.យ៉កស៍(ខេមបូឌា) | ០១នាក់ |
| ៦.អ៊ីលីត (ខេមបូឌា) | ០១នាក់ |





ហេតុការណ៍គ្រោះថ្នាក់ខាងលើនេះជាគ្រោះថ្នាក់ការងារ ដូចនេះមន្ត្រី ប.ស.ស ខេត្តបានចុះជួយសម្របសម្រួល និងបានបញ្ជូន ជនរងគ្រោះទៅសង្គ្រោះ និងព្យាបាលនៅមន្ទីរពេទ្យបង្អែកស្វាយទាប ខេត្តស្វាយរៀង។ រាល់សេវាដឹកជញ្ជូន និងសេវាព្យាបាលរហូតដល់ជា សះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។



*រូបភាពជនរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ*

# បេឡាជាតិរបបសន្តិសុខសង្គម បានចុះសួរសុខទុក្ខ និងប្រគល់ សម្ភារៈស្តារនីតិសម្បទាជូនជនរងគ្រោះ ដែលជាសមាជិក ប.ស.ស

កំពង់ចាម-ត្បូងឃ្មុំ៖ **បេឡាជាតិរបបសន្តិសុខសង្គម** នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់អត្ថប្រយោជន៍ដល់សមាជិករបស់ ខ្លួនយ៉ាងច្រើន សម្រាប់ការអនុវត្តលើរបបសន្តិសុខសង្គម រយៈពេល១០ឆ្នាំកន្លងមក ក្នុងនោះមានការផ្តល់សម្ភារៈស្តារនីតិសម្បទាជូនជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ) នៅពេលសមាជិកទទួលរងគ្រោះថ្នាក់ដោយប្រការណាមួយដែលការងារនេះជាបន្ទុករបស់ ប.ស.ស។

ថ្មីៗនេះដែរ ក្រុមការងារស្តារនីតិសម្បទានៃ **បេឡាជាតិរបបសន្តិសុខសង្គម** បានចុះផ្តល់រទេះជនពិការ ឈើច្រត់ និងតាមដានការផ្តល់សេវាស្តារនីតិសម្បទាដល់លំនៅដ្ឋានជនរងគ្រោះចំនួន០៤រូប ស្ថិតនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលមានរាយនាមដូចខាងក្រោម៖

ជនរងគ្រោះទី១ មានឈ្មោះ **ឈៀង ស្រីពេជ្រ** ភេទស្រី អាយុ២០ឆ្នាំ បច្ចុប្បន្នស្នាក់នៅខេត្តកំពង់ចាម បានរងគ្រោះថ្នាក់នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៦ និង ៤០នាទី ដោយ រថយន្តដឹកកម្មករនិយោជិតបានក្រឡាប់ ខណៈកំពុងបើកបរក្នុងទិសដៅពីផ្ទះទៅកន្លែងធ្វើការ បណ្តាលឱ្យរងរបួសជើងទាំង សងខាង (ត្រូវបានកាត់ជើងខាងស្តាំ)។



រូបភាព: ជនរងគ្រោះទី១

តាមការពិនិត្យហ្វីល ដែលជនរងគ្រោះបានទៅពិនិត្យព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត ឃើញថាធូរស្រាលច្រើន ឆ្អឹងបានដុះមកវិញជាបណ្តើរៗ ហើយ ប.ស.ស បានផ្តល់នូវរទេះជនពិការមួយ និងឈើច្រត់មួយ។



ការពិនិត្យហ្វីល ជនរងគ្រោះទី១

ជនរងគ្រោះទី២ មានឈ្មោះ **ភួយ សុខ** ភេទប្រុស អាយុ៤៦ឆ្នាំ បច្ចុប្បន្នស្នាក់នៅខេត្តកំពង់ចាម បានរងគ្រោះថ្នាក់នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង ០៤ និង ០០នាទី ដោយវិលមុខដើរធ្លាក់លូ នៅកន្លែងធ្វើការបណ្តាល ឱ្យរងរបួសមួយចំហៀងខាងស្តាំពីក្បាលដល់ចុងជើង និងរាង្គកាយមួយចំនួនទៀត។



រូបភាព: ជនរងគ្រោះទី២

ជនរងគ្រោះទី៣ មានឈ្មោះ **ឈួន សាវ៉ៃ** ភេទស្រី អាយុ ៥២ឆ្នាំ បច្ចុប្បន្នស្នាក់នៅខេត្តកំពង់ចាម បានរងគ្រោះថ្នាក់នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ០៧ និង០០ នាទី ដោយម៉ូតូ និងម៉ូតូបុកគ្នាក្នុងទិសដៅត្រង់ពីផ្ទះទៅកន្លែងធ្វើការ បណ្តាលឱ្យរងរបួសខ្ទាំក្បាល និងបាក់ឆ្អឹងកំភួនជើងខាងស្តាំរីឯ ស្ថានភាពរបួសនៅពេលនេះបានធូរស្បើយ និងបានដកដែកអបជើងចេញវិញ និងបន្តប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា គ្រូពេទ្យ។

ជនរងគ្រោះទី៤ មានឈ្មោះ **ឈុន ឡេង** ភេទស្រី អាយុ ៣៨ឆ្នាំ បច្ចុប្បន្នស្នាក់នៅខេត្តត្បូងឃ្មុំ បានរងគ្រោះថ្នាក់នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៦ និង ០៦នាទី ដោយជិះម៉ូតូបុកបង្គោលស៊ីម៉ង់ត៍ដាក់តាមគម្របលូក្នុងទិសដៅពីកន្លែងធ្វើការទៅផ្ទះដោយត្រង់ បណ្តាលឱ្យរងរបួសបាក់ឆ្អឹងភ្លៅក្បាលជង្គង់ និងស្មងជើង ចំណែកឯស្ថានភាពរបួសវិញ គឺមិនទាន់ដកដែកអមភ្លៅនៅឡើយទេ ព្រមទាំងវះកាត់យកឆ្អឹងខ្ទីពីត្រគៀកមកប៉ះត្រង់ភ្លៅ និងជង្គង់។


រូបភាព: ជនរងគ្រោះទី៣


រូបភាព: ជនរងគ្រោះទី៤

ជាការពិតណាស់រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដែលជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យម ដើម្បីកំណត់ឱ្យបានច្បាស់នូវគោលនយោបាយ និងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់សុខុមាលភាពជនពិការ។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលវែង ២០១៦-២០២៥ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដើម្បីធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះ ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់ប្រជាជន សំដៅលើកកម្ពស់សុខុមាលភាព និងសាមគ្គីភាពក្នុងសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្រជាអតិបរមាដែលផ្តោតលើសសរស្តម្ភចំនួន ០២គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ដោយផ្នែកពិការភាពត្រូវបានរាប់បញ្ចូលក្នុងធាតុផ្សំទី៥ ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងនោះបងប្អូនកម្មករ និយោជិតត្រូវបានធានារ៉ាប់រងដោយបេឡាជាតិរបបសន្តិសុខសង្គម៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...០១២៨...សខល

ថ្ងៃពុធ..៧.កើត.ខែផល្គុន..ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជម្រាបជូន**

## ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល

**កម្មវត្ថុ:** ការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈជូនដល់បុគ្គលិក និងអ្នកជំនាញដោះមីន នៃប្រតិបត្តិករបោសសម្អាតមីន។

**យោង** អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងឱកាសចុះសំណេះសំណាលជាមួយបងប្អូនកម្មករ និយោជិត នៅតំបន់វត្តទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ក្រសួងសុខាភិបាលសូមជម្រាបជូន **ឯកឧត្តម លោក លោកស្រី ប្រធាន** ជ្រាបថា: មូលដ្ឋានសុខាភិបាលសាធារណៈ រួមមានមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព មន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ ត្រូវអនុវត្តការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃជូនបុគ្គលិក និងអ្នកជំនាញដោះមីននៃប្រតិបត្តិករបោសសម្អាតមីនទាំងអស់ ចាប់ពីថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅ។

ក្នុងការផ្តល់សេវាថែទាំសុខភាព ជូនបុគ្គលិក និងអ្នកជំនាញដោះមីននៃប្រតិបត្តិករបោសសម្អាតមីន មូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ត្រូវអនុវត្ត តាមខ្លឹមសារណែនាំដូចខាងក្រោម:

- នៅពេលមកប្រើប្រាស់សេវា ពួកគាត់ត្រូវបង្ហាញប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដែលចេញដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ប័ណ្ណសម្គាល់ខ្លួនដែលចេញដោយអង្គភាពសាមី និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (បើមាន)។
- ក្នុងករណីដែលមិនទាន់មានប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដែលចេញដោយ ប.ស.ស ពួកគាត់នៅតែទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ។
- ការប្រើប្រាស់សេវាត្រូវចាប់ផ្តើមពី មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព លើកលែងតែករណីត្រូវការសង្គ្រោះបន្ទាន់។ ការប្រើប្រាស់សេវានៅមន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ ត្រូវមានលិខិតបញ្ជូនពីមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកថ្នាក់ក្រោម លើកលែងតែករណីត្រូវការសង្គ្រោះបន្ទាន់។
- កញ្ចប់សេវាថែទាំសុខភាពសម្រាប់ពួកគាត់ ត្រូវអនុវត្តដូចគ្នានឹងកញ្ចប់សេវាថែទាំសុខភាពនៃកម្មវិធីមូលនិធិសមធម៌សុខាភិបាលដែលកំពុងអនុវត្តសម្រាប់កម្មករក្រៅប្រព័ន្ធដែរ។

- ការទូទាត់ថ្លៃសេវាថែទាំសុខភាព ដល់មូលដ្ឋានសុខាភិបាលសាធារណៈ នៅក្រោមកម្មវិធីមូលនិធិសមធម៌ជាបន្ទុករបស់ក្រសួងសុខាភិបាល។
- មូលដ្ឋានសុខាភិបាលសាធារណៈត្រូវកត់ត្រា និងរក្សាទុកឯកសារ ឬបញ្ជីស្វាមចាំបាច់នានា ដែលទាក់ទងនឹងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ពួកគាត់ សម្រាប់ស្នើសុំទូទាត់ថ្លៃសេវាពីមូលនិធិសមធម៌សុខាភិបាល និងសម្រាប់ផ្តល់ព័ត៌មានទៅ ប.ស.ស ដើម្បីពន្លឿនការចុះបញ្ជីជាសមាជិក ប.ស.ស។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធិភាពដោយការទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅ។

សូម **ឯកឧត្តម លោក លោកស្រី ប្រធាន** ទទួលនូវការគោរពអានដ៏ស្មោះ អំពីខ្ញុំ ។

ម៉ម ប៊ុនហេង

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- បេឡាជាតិរបបសន្តិសុខសង្គម
- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- អង្គភាពពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០០១ ស.ជ.ល

ថ្ងៃពុធ ២ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ជម្រាបជូន**
**ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល**

**កម្មវត្ថុ:** ការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈជូនដល់កម្មករ ជាក់ស៊ីក្លូ ចាប់ពីថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨។

**យោង:**- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ក្នុងឱកាសចុះសំណេះសំណាលជាមួយបងប្អូនកម្មករ និយោជិត នៅតំបន់ទួលសង្កែ (ផ្សារសាំហាន់) ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងសុខាភិបាលសូមជម្រាបជូនឯកឧត្តម លោក លោកស្រី ប្រធានអង្គភាពសុខាភិបាលគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសជ្រាបថា មូលដ្ឋានសុខាភិបាលសាធារណៈ រួមមានមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព មន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិត្រូវអនុវត្តការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃដល់កម្មករជាក់ស៊ីក្លូ ចាប់ពីថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨តទៅ។

ក្នុងការផ្តល់សេវាថែទាំសុខភាព មូលដ្ឋានសុខាភិបាលសាធារណៈត្រូវអនុវត្តតាមខ្លឹមសារណែនាំដូចខាងក្រោមនេះ៖

- នៅរាល់ពេលមកប្រើប្រាស់សេវាកម្មករជាក់ស៊ីក្លូ ត្រូវបង្ហាញប័ណ្ណមូលនិធិសមធម៌ដែលចេញដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (បើមាន)។
- ក្នុងករណីដែលកម្មករស៊ីក្លូមិនទាន់មានប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដែលចេញដោយ ប.ស.ស កម្មករស៊ីក្លូនោះនៅតែទទួលបានសេវាថែទាំសុខភាពដោយឥតបង់ថ្លៃ។
- ការប្រើប្រាស់សេវាត្រូវចាប់ផ្តើមពី មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព លើកលែងតែករណីត្រូវការសង្គ្រោះបន្ទាន់។ ការប្រើប្រាស់សេវានៅមន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ មន្ទីរពេទ្យបង្អែក





ព្រឹត្តិបត្រព័ត៌មាន ៣២
បេឡាជាតិរបបសន្តិសុខសង្គម

រាជធានី/ខេត្ត មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ ត្រូវមានលិខិតបញ្ជូនពីមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកថ្នាក់ក្រោម លើកលែងតែករណីត្រូវការសង្គ្រោះបន្ទាន់។

- កញ្ចប់សេវាថែទាំសុខភាពសម្រាប់កម្មករជាក់ស៊ីក្លូ ត្រូវអនុវត្តដូចគ្នានឹងកញ្ចប់សេវាថែទាំសុខភាពនៃកម្មវិធីមូលនិធិសមធម៌សុខាភិបាលដែលកំពុងអនុវត្ត សម្រាប់កម្មករក្រៅប្រព័ន្ធដែរ។
- ការទូទាត់ថ្លៃសេវាថែទាំសុខភាពដល់មូលដ្ឋានសុខាភិបាលសាធារណៈ នៅក្រោមកម្មវិធីមូលនិធិសមធម៌ជាបន្ទុករបស់ក្រសួងសុខាភិបាល។
- មូលដ្ឋានសុខាភិបាលសាធារណៈត្រូវកត់ត្រា និងរក្សាទុកឯកសារ ឬបញ្ជីស្នាមចាំបាច់នានា ដែលទាក់ទងនឹងការប្រើប្រាស់សេវាថែទាំសុខភាពរបស់កម្មករជាក់ស៊ីក្លូសម្រាប់ការស្នើសុំទូទាត់ថ្លៃសេវាពីមូលនិធិសមធម៌សុខាភិបាល និងសម្រាប់ផ្តល់ព័ត៌មានទៅ ប.ស.ស ដើម្បីពន្លឿនការចុះបញ្ជីជាសមាជិក ប.ស.ស។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាលត្រូវយកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាព ដោយការទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ តទៅ។

សូមឯកឧត្តម លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

សាស្ត្រាចារ្យ ម៉ម ប៊ុនហេង

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- បេឡាជាតិរបបសន្តិសុខសង្គម
- សាលារាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ



ព្រឹត្តិបត្រព័ត៌មាន ៣៣
បេឡាជាតិរបបសន្តិសុខសង្គម

# ជំងឺលើសសម្ពាធឈាម និងទឹកនោមផ្អែមខ្លាចបន្លែ ៣ មុខនេះ

ជំងឺលើសសម្ពាធឈាម និងទឹកនោមផ្អែមខ្លាចបន្លែ ៣ មុខ នេះណាស់ប្រសិនជាអ្នកចង់គ្រប់គ្រងសម្ពាធឈាម និងជាតិស្ករក្នុងខ្លួនអ្នកមិនឱ្យឡើង អ្នកអាចជ្រើសរើសបន្លែទាំង ៣ប្រភេទនេះដើម្បីពិសារបាន។

តើមានអ្វីខ្លះទៅ?

### ១-ត្រឡាច



វាជាបន្លែដែលអាចជួយទប់មិនឱ្យសម្ពាធឈាម និងជាតិស្ករក្នុងខ្លួនអ្នកឡើងខ្ពស់ឡើយ។ ជាពិសេសវាថែមទាំងអាចជួយការពារអ្នកមិនឱ្យងាយចាស់ស្បែក ព្រមទាំងធ្វើឱ្យស្បែកភ្លឺ ហើយម៉ត់រលោងជាមិនខាន។

### ២-ការ៉ុត



ជាបន្លែដែលអាចជួយការពារអ្នកពីជំងឺទាំង ២ ប្រភេទខាងលើដែរ។ មិនត្រឹមតែប៉ុណ្ណោះ វានឹងជួយធ្វើឱ្យភ្នែកអ្នកភ្លឺ ថែមទាំងជួយឱ្យថ្លើម និងពោះវៀនមានសុខភាពល្អទៀតផង។ ជាពិសេសវាក៏អាចជួយបង្កើនប្រព័ន្ធការពាររាងកាយរបស់អ្នកឱ្យរឹងមាំផងដែរ។

### ៣-ផ្កាខាត់ណា



ជាបន្លែដែលសម្បូរវីតាមីនសេ ដែលអាចជួយថ្លើមអ្នកឱ្យបញ្ចេញជាតិពុលចេញមកក្រៅអស់។ វាមិនត្រឹមតែអាចការពារអ្នកពីជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែមទេ ថែមទាំងអាចជួយការពារអ្នកឱ្យចៀសពីជំងឺបេះដូងទៀតផង។ ជាពិសេសអ្នកនឹងមិនងាយប្រឈមមុខនឹងជំងឺមហារីកនោះទេ៕

# វិធីងាយៗកំចាត់មុន និងធ្វើឱ្យមុខស្រស់ថ្លា

ចាប់ពីថ្ងៃនេះទៅ មិត្តនារីទាំងឡាយនឹងអស់កង្វល់ពីរឿងកើតមុន និងជួយធ្វើឱ្យមុខស។ ខាងក្រោមនេះជាការបង្ហាញអ្នកពីរបៀបកំចាត់មុន និងធ្វើឱ្យមុខស។



១-អ្នកគួរតែញ៉ាំទឹកឱ្យបានច្រើន ដោយមួយថ្ងៃគួរតែញ៉ាំឱ្យបាន៨កែវ។ ស្បែកត្រូវការទឹក បើគ្មានទឹកគ្រប់គ្រាន់ទេ ស្បែកអ្នកនឹងប្រែជាស្ងួត ហើយងាយកើតមុនជាទីបំផុត។

២-អ្នកគួរតែចៀសឱ្យឆ្ងាយពីអាហារដែលបំពងខ្លាញ់ និងហិរទាំងឡាយ។ អាហារទាំងនេះ នឹងធ្វើឱ្យមុខអ្នកកើតមុនកាន់តែច្រើនទៅៗជាមិនខានឡើយ។

៣-អ្នកគួរតែបរិភោគអាហារដែលមានសារធាតុចិញ្ចឹមច្រើនដូចជា ៖ ទឹកដោះគោ បន្លែ ផ្លែឈើ។ អាហារ ទាំងនេះនឹងជួយអ្នកទប់ទល់នឹងមុនមិនឱ្យវាកើតឡើយ៕

ប្រភព៖ http://news.sabay.com.kh



# អ្នកគិរម្យភាសាអ៊ូ ហៅ ង៉ុយ

កើតក្នុងឆ្នាំ ១៨៦៥ (ព.ស ២៤០៨) ភូមិព្រៃអណ្ដូងស្វាយ ឃុំកំបូល ស្រុកភ្នំពេញ
(បច្ចុប្បន្នស្រុកអង្គស្នួល) ខេត្តកណ្ដាល ។
ត្រូវបានទទួលអនិច្ចកម្មក្នុងឆ្នាំ ១៩៣៦ ក្នុងជន្មាយុ ៧១ឆ្នាំ។

## បណ្ដាំក្រមង៉ុយ

ចង់ធំខំពីតូច
បើខ្លាចខូចកុំឆាប់ខឹង
ការធ្វើឱ្យចេះថ្លឹង
កុំប្រឹងផុះតាមដំរី។
កុំចង់ខ្ពស់ស្មើមេឃ
កុំឱនពេកអាប់រាសី
ទោះដើរនិយាយស្ដី
លៃឱ្យល្មមតែគួរសម។
យល់ឆ្ងាយកុំណាយគិត
ទោះយល់ជិតកុំអាលខំ
មិនជាក់មើលឱ្យចំ
ក្រែងច្រឡំសជាខ្មៅ។
ទន្លាប់ធំជាងច្បាប់
បើរៀនគ្រាប់កុំតាមខ្មៅ
គ្រាប់ប្រាជ្ញអាចប្រដៅ
ស្ដីកូនចៅស្ដីឱ្យស្មោះ។

ដកស្រង់ពីបណ្ដាំក្រមង៉ុយ ជាបទព្រហ្មគីតិ និពន្ធឡើងក្នុងរវាងឆ្នាំ១៩៣៥

# កូនមាសពន្លក

-កូនសម្លាញ់ម្តាយកុំរៀនស្តីជេរ កុំពោលកាច់គេណាមាសកូនអើយ
បើមានសំណួរណាពុំគួរឆ្លើយ ឪកូនប្រាប់ហើយឆ្លើយត្រឹមញញឹម។
-បណ្តាំឪកូន **ក.ខ** នាំមុខ **ក** ជួរក្រោយទុកឱ្យកូនសង្ឃឹម

**ក**- កូនមាសស្ងួន នួនមាសឪពុ **ក**
**ខ**- ខានជួបមុខ ពុកម៉ែសែននឹ **ក**
**គ**- គិតដល់កូនរាល់ពេលល្ងាចព្រឹ **ក**
**ឃ**- ឃើញបាយទឹកនឹកកូនពន់ពេ **ក**។
**ង**- ងុយយប់ជ្រៅ ទៅដេកពុំល **ក់**
**ច**- ចិត្តរីរក់ ម្តាយកូនទឹកភ្នែ **ក**
**ឆ**- ឆាប់មកពៅ កុំនៅយូរពេ **ក**
**ជ**- ជួបជដែក ម្តាយចង់ យល់ភ **ក្ត្រ**។
**ឈ**- ឈប់ឆេវឆាវ ទៅពៅពន្ល **ក**
**ញ**- ញាតិរាប់រក ញញឹម រាក់ទា **ក់**
**ដ**- ដឹងគុណទោស ចេះស្គាល់ជ្រៅរា **ក់**
**ឋ**- ឋិតថេរជាក់ គ្មានអ្នកអន់អា **ក់**។
**ឌ**- ឌីឌៀមឌាម នេះនាំឈឺចុ **ក**
**ឍ**- វឌ្ឍនៈសុខ កុំបីថ្នាំងថ្នា **ក់**
**ណ**- ណែនាំផ្លូវ ម៉ែឪទុកដា **ក់**
**ត**- តាមបុណ្យសក្តិ កុំស៊ីល្មួចលា **ក់**។
**ថ**- ថែទាំខ្លួន នួនមាសឪពុ **ក**
**ទ**- ទៅថ្ងៃមុខ ពុកម៉ែពឹងអ្ន **ក**
**ធ**- ធនធានមានញាតិហ៊ានពឹងពា **ក់**
**ន**- នាំឱ្យអ្នករុងរឿងអនេ **ក**។
**ប**- បើបាត់មុខ បាត់ឱ្យគេនឹ **ក**
**ផ**- ផឹកត្រឹមទឹក ស្មារតីល្អឯ **ក**
**ព**- ពាក្យពិសពុល នាំឈ្លោះប្រកែ **ក**
**ភ**- ភ័យអល់អែក ព្រោះបែកបា **ក់**។
**ម**- មិត្តផឹកស៊ី កុំសង្ឃឹមពេ **ក**
**យ**- យប់ចូលដេក កុំភ្លេចទុកដា **ក់**
**រ**- រៀនរកស៊ី កុំហ៊ានហួសប្រា **ក់**
**ល**- លុយជំពាក់ តែងនាំទឹកភ្នែ **ក**។
**វ**- វ័យសិក្សា រៀនឱ្យជាក់លា **ក់**
**ស**- សូមឱ្យអ្នក ចេះគិតរែកញែ **ក**
**ហ**- ហាត់សូត្រធម៌ មុនចូលដំណេ **ក**
**ឡ**- ឡើងពីដេក កុំនៅសំកុ **ក**។
**អ**- អស់ពីឪ ពៅត្រូវលៃល **ក**
**ក.ខ**- យកមករស់ជុំ អ្នកស្រុ **ក**
**ក**- ជួរក្រោយនៅ ត្រូវចាំពាក្យពុ **ក**
**ឥ**- ទៅថ្ងៃមុខ កាន់តែលំបា **ក**។៚

**ដោយឧបាសក គុយ សុធន**
ដកស្រង់៖ សៀវភៅកូនមាសឪពុក
ទំព័រទី ១៤២ ដល់ ១៤៤

ព្រឹទ្ធបុត្រព័ត៌មាន ៣៦
បញ្ញាជាតិរបបសន្តិសុខសង្គម




១- ជីវិតតាមពិតសាមញ្ញខ្លាំងណាស់ តែយើងចេះតែធ្វើឱ្យវាស្មុគស្មាញ
ម៉ែស្រលាញ់កូនឥតមានអ្វីផ្ទឹម ពុកកូនសង្ឃឹមតែងជួយរំលឹក។

២- គ្រប់យ៉ាងសុទ្ធតែស្រស់បំព្រង តែមិនមែនគ្រប់គ្នាបានឃើញទេ។

៣-ជ្រើសរើសការងារដែលស្រលាញ់អ្នកនឹងគ្មានអារម្មណ៍ថា កំពុងធ្វើការ សូម្បីមួយថ្ងៃ។

៤- អ្វីដែលមិនចង់ឱ្យកើតលើខ្លួនអ្នក កុំធ្វើលើអ្នកដទៃ។

៥- វាងាយស្រួលណាស់ក្នុងការស្អប់ តែពិបាកក្នុងការស្រលាញ់។













# ប.ស.ស បេឡាជាតិរបបសន្តិសុខសង្គម

## National Social Security Fund


អាសយដ្ឋាន: អាគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: (០២៣) ៨៨ ២៤ ៣៤ / ៩៩ ៤៤ ១៧

(០២៣) ៩៩ ៤៤ ១៨ / ៩៩ ៤៤ ១៩

គេហទំព័រ: www.nssf.gov.kh

អ៊ីម៉ែល: info@nssf.gov.kh